00942630

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01/05/2013
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/200

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ១៨៧

រៀបចំដោយ៖ **ដាវ អានសាន** និង **Miriam MAFESSANTI**

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, កញ្ញា Miriam MAFESSANTI, លោកស្រី Faiza ZOUAKRI, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់តារាស្មី, លោក Vincent De Wilde d'Estmael |
| ជនជាប់ចោទ៖ ខៀវ សំផន និង នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Anta GUISSÉ |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក Pascal AUBOIN, លោកស្រី Beini YE, លោក សំ សុគង់, លោក វ៉ែន ពៅ, លោកស្រី Christine MARTINEAU, លោក Emmanuel JACOMY, លោកស្រី ស៊ិន សុវ៉ន, លោកស្រី Nushin SARKARATI |
| ដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី បេ សុផានី (TCCP-4), លោក សឿន សុវណ្ណី (TCCP-145), លោកស្រី សេង ស៊ីវុត្ថា (TCCP-141) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្ល សុធាវី |
| ផ្សេងៗ៖ កញ្ញា Virginia THOMPSON |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖១៥.៥០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖១១.០០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.២៥ | បញ្ចប់ម៉ោង៖១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៥.០០ | បញ្ចប់ម៉ោង៖ ១៥.២០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការលះបង់សិទ្ធិមានវត្តមានក្នុងសវនាការ | អជសដ | ០៩.០៩ | ០៩.០៩ |
| ការថ្លែងអំពីទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បេ សុផានី (TCCP-4) | អង្គជំនុំជម្រះ | ០៩.១៣ | ០៩.១៦ |
| | មេធាវីដើមបណ្ដឹងរ/វេណី | ០៩.១៧ | ១០.០២ |
| | ខៀវ សំផន | ១០.០៣ | ១០.០៧ |
| | នួន ជា | ១០.០៨ | ១០.១០ |
| | តំណាងសហព្រះរាជអាជ្ញា | ១០.១០ | ១០.២៩ |
| | មេធាវីដើមបណ្ដឹងរ/វេណី | ១០.៣០ | ១០.៤០ |
| | ក្រុមមេធាវី នួន ជា | ១១.០១ | ១១.២២ |
| | ក្រុមមេធាវី ខៀវ សំផន | ១១.២២ | ១១.២៣ |
| ការថ្លែងអំពីទុក្ខសោក និងព្យសនកម្មរបស់ | អង្គជំនុំជម្រះ | ១១.២៦ | ១១.៣០ |

| | | | |
|---|---|---|---|
| ដើមបណ្ដឹងរដ្ឋប្បវេណី សឿន សុវណ្ណី (TCCP-145) | ដើមបណ្ដឹងរដ្ឋប្បវេណី | ១១.៣០ | ១១.៤០ |
| | មេធាវីដើមបណ្ដឹងរ/វេណី | ១១.៤០ | ១២.១១ |
| | ខៀវ សំផន | ១២.១១ | ១២.១៨ |
| | នួន ជា | ១២.១៩ | ១២.២២ |
| | តំណាងសហព្រះរាជអាជ្ញា | ១៣.៣៤ | ១៣.៥១ |
| | ក្រុមមេធាវី នួន ជា | ១៣.៥១ | ១៣.៥២ |
| | ក្រុមមេធាវី ខៀវ សំផន | ១៣.៥២ | ១៤.១៩ |
| ការថ្លែងអំពីទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា (TCCP-141) | អង្គជំនុំជម្រះ | ១៤.២២ | ១៤.២៧ |
| | មេធាវីដើមបណ្ដឹងរ/វេណី | ១៤.២៧ | ១៥.២៨ |
| | ខៀវ សំផន | ១៥.២៨ | ១៥.៣១ |
| | ក្រុមការពារក្ដី នួន ជា | ១៥.៣២ | ១៥.៣៣ |
| | តំណាងសហព្រះរាជអាជ្ញា | ១៥.៣៣ | ១៥.៤៦ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការលះបង់សិទ្ធិមានវត្តមានក្នុងសវនាការ**

ជនជាប់ចោទ នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយអនុវត្តវិធាន ៨១ (៥) នៃវិធានផ្ទៃក្នុង (សូមមើលសេចក្ដីសម្រេចស្ដីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5, ចុះថ្ងៃទី ០២ មេសា ២០១៣)។

**ការថ្លែងអំពីទុក្ខសោកនិងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បេ សុផានី (TCCP-4)**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បេ សុផានី (TCCP-4)។ បន្ទាប់មក មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណី សួរសំណួរ ៣ ដល់ជនជាប់ចោទទាំងពីរ។ ជនជាប់ចោទ ខៀវ សំផន និង នួន ជា ឆ្លើយតបសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ជាបន្តបន្ទាប់ សហព្រះរាជអាជ្ញា មេធាវីការពារក្ដី នួន ជា តាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្ដល់ពេលវេលាបន្ថែម ៥នាទី ដើម្បីតាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់ពីការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា។

**ការថ្លែងអំពីទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សឿន សុវណ្ណី (TCCP-145)**

អង្គជំនុំជម្រះតាំងសំណួរទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សឿន សុវណ្ណី (TCCP-145)។ ដើមបណ្ដឹងរដ្ឋប្បវេណីថ្លែងអំពីទុក្ខសោក និងព្យសនកម្មដែលបានទទួលរងនៅរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរចំនួន ៣ ដល់ជនជាប់ចោទទាំងពីរ ហើយលោក ខៀវ សំផន និងលោក នួន ជា ឆ្លើយនឹងសំណួរ។ បន្ទាប់មក សហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី ខៀវ សំផន តាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**ការថ្លែងអំពីទុក្ខសោក និងព្យសនកម្មរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា (TCCP-141)**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា (TCCP-141)។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីទុក្ខសោក និងព្យសនកម្មដែលបានទទួលរងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរ ២ ដល់ជនជាប់ចោទទាំងពីរ។ ជនជាប់ចោទ ខៀវ សំផន ឆ្លើយតបនឹងសំណួរ។ តំណាងសហព្រះរាជអាជ្ញាសួរសំណួរបញ្ចប់ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខកសចស | ERN | ចំណងជើង | ចំណាត់ថ្នាក់ | សម្គាល់ជាភាសាខ្មែរ | សម្គាល់ជាភាសាអង់គ្លេស | សម្គាល់ជាភាសាបារាំង |
|---|---|---|---|---|---|---|---|
| E3/4619 | D22/3850 | 00865219-00865226, 00571050-00571075 00867203-00867211 00860735-00860745, 00846057-00846072 | [Partial.T] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ BAY Sophany 10-VU-00619 [Partial.T] Civil party application of BAY Sophany 10-VU-00619 Constitution de partie civile de BAY Sophany 10-VU-00619 | P | 00571064 | 00867208 | 00860741-42 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| N/A | E285.1.1 | 00910045-00910163 | Attachment 1: Beth Van Schaack, Daryn Reicherter and Youk Chhang, eds., Cambodia Hidden Scars. Trauma Psychology in the Wake of the Khmer Rouge, (Phnom Penh: DC-Cam, 2011) | P | | 00910047 | |
| E3/4620 | D22/2745/1 | 00556030-00556032 | Victim Unit's report on the civil party applicant | P | | 00556030 | |
| E3/4621 | D22/2745a | 00579163-00579164 00865120-00865121 00909167-00909167 | ឯកសារបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី Supplementary information of civil party applicant/Document d'information supplementaire de partie civile Supplementary information of civil party applicant/Document d'information supplementaire de partie civile | P | 00579163 | 00865120 | 00909167 |
| E3/4622 | D22/3804 | 00570336-005703480 0911396-00911402 | ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ស៊ីវុត្ថា SENG Sivutha 10-VU-00382 [Partial T.] Demande de constitution de partie civile de SENG Sivutha 10-VU-00382 | P | | | |
| N/A | E9/32.2.16 | 00678187-006781890 0916956-00916958 | កំណត់ហេតុបន្ថែមរបស់ សេង ស៊ីវុត្ថា Informations complémentaires de SENG Sivutha | P | | | |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះតែងតាំងចៅក្រមបម្រុង ធូ មណី ជាចៅក្រមពេញសិទ្ធិ ជំនួស ចៅក្រម យូរ ឧត្តរា ដែលអវត្តមានដោយមានបញ្ហាសុខភាព ស្របតាមវិធាន ៧៩ (៤) នៃវិធានផ្ទៃក្នុង។
- ជូនដំណឹងដល់ភាគីអំពីការផ្លាស់ប្ដូរកាលវិភាគសវនាការ ពោលគឺ នៅថ្ងៃទី ០៥, ០៦ និង ០៧ ខែ មិថុនា ឆ្នាំ ២០១៣ នឹងចាប់ផ្ដើមនៅម៉ោង ០៨.៣០ ព្រឹក និងសម្រាកពេលថ្ងៃត្រង់នៅម៉ោង ១១.៣០នាទី។
- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្ដឹងលោកស្រី បេ សុផានី (TCCP-4), លោក សឿន សុវណ្ណី (TCCP-145), លោកស្រី សេង ស៊ីវុត្ថា (TCCP-141) ត្រឡប់ទៅកាន់លំនៅដ្ឋានវិញ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការវិញ និងជនជាប់ចោទ នួន ជា មកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ឲ្យបានមុន ម៉ោង ០៨.៣០ នាទី ព្រឹក ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ០៨.៣០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣

ក្រឡាបញ្ជី [illegible]

**ដាច អាន [illegible] Miriam MAFESSANTI**